**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ជូនចំពោះ ឯកឧត្តម ប្រាំ សុខា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង លោកជំទាវ**

ប្រជាជនកម្ពុជាយើងកំពុងតែប្រឈមនឹងហានិភ័យ ដែលបង្កឡើងដោយជំងឺរាលដាល កូវីដ-១៩ (COVID-19)។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលសូមថ្លែងអំណរគុណ និងកោតសរសើរដោយស្មោះចំពោះ ឯកឧត្តម និងលោកជំទាវ ដែលបានបរិច្ចាគនូវជំនួយជាថវិកាចំនួន ១០.០០០$ (ដប់ពាន់ដុល្លារ) អាមេរិក ជូនដល់រាជរដ្ឋាភិបាល សម្រាប់ប្រយុទ្ធប្រឆាំងនឹងជំងឺដ៏កាចសាហាវមួយនេះ ជាកិច្ចបំពេញកាតព្វកិច្ចការពារ និងសង្គ្រោះសុខភាព និងជីវិតប្រជាជនកម្ពុជា។

សូមឯកឧត្តម និងលោកជំទាវ បានជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ ព្រហស្បត្តិ៍ ១០ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០

**ហ៊ុន សែន**

CS Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ១៥៦៩ មស.រប

**សូមគោរពជូន**

**- ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**- ឯកឧត្តមវេជ្ជបណ្ឌិតសាស្ត្រាចារ្យ រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងឯកឧត្តមរដ្ឋមន្ត្រី ជាទីគោរពរាប់អាន!

គោរពប្រតិបត្តិតាមគំរូវីរភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបរិការណ៍ដែលស្ថានភាពជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ កូវីដ-១៩ បាន និងកំពុងបន្តរីករាលដាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមចូលរួមសម្តែងនូវសមានចិត្ត តាមរយៈការស្ម័គ្រចិត្តជូនទៅគណៈកម្មាធិការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ នូវប្រាក់បៀវត្សរបស់ខ្ញុំ ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងមុខងារសាធាណៈ ចំនួន ៦ ខែ ដោយគិតចាប់ពីខែមេសា រហូតដល់ខែកញ្ញា ឆ្នាំ២០២០ ។

ក្នុងន័យនេះ ខ្ញុំសូម ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេត្តាចាត់ចែងបង្វែរប្រាក់បៀវត្សរបស់ខ្ញុំដូចបានជម្រាបជូនខាងលើទៅក្នុងគណនីរបស់គណៈកម្មាធិការជាតិប្រយុទ្ធនឹង ជំងឺកូវីដ-១៩ (COVID-19) តាមការគួរ ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង **ឯកឧត្តមរដ្ឋមន្ត្រី** ទទួលនូវការគោរពរាប់អានពីខ្ញុំ ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០២០
**រដ្ឋមន្ត្រី**

**ព្រុំ-សុខា**

ចម្លងជូន:
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ឯកសារ-កាលប្បវត្តិ

ផ្លូវវិក្រមអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh